D. CIVILISATION ANCIENNE
N° Du 2612

ព្រះរាជបណ្ណាល័យកម្ពុជា

# CAMPUCHÉA SAURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់បួន

ខ្សែ ២

ក្រសួងសេនាបតីបានអនុញ្ញាតហើយ

PER 933




ក្រុងភ្នំពេញ
រោងពុម្ពអាលបែរពរតៃ
គ្រិ. ឆ្នាំ ១៩៣២
ព. ស. ២៤៧៥

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

អ្នកទទួលខុសត្រូវ : ជុំ-មៅ

# បញ្ជីរឿង

ទំព័រ


១ អំពីរូបព្រះអរិយមេត្រីយនៅសារមន្ទីរក្រុងព្រៃនគរ អ្នកស្រីការប៉ីឡេសអធិប្បាយ.. ៣

២ មិលិន្ទបញ្ហា ព្រះឧត្តមមុនី អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីបាឡី (ត) . . . . . . . . . . . . . . . . . . . . ៤

៣ ប្រស្នាធមិសត្តកណ្ហបនឹងគ្រុឌ ព្រះញាណបវរវិជ្ជា អែម ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ប្រែពីបាលីគម្ពីរបញ្ញាសជាតក . . . . . . . . . . . . . . . ២១

៤ រឿងបុរស ៣ នាក់ឈ្មោះគ្នា, ដកយកពីរឿងព្រេងខ្មែរក្នុងសៀវភៅលោក អេម៉ូនិញេ . . . . . . . . . . . . . . . . . . . . . . . . ៣៧


# រូបថត


រូបព្រះអរិយមេត្រីយពោធិសត្វ ក្នុងសារមន្ទីរក្រុងព្រៃនគរ . . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1° Description d'une statue de Maitreya au Musée de Saigon par S. Karpelès, Conservateur de la Bibliothèque Royale. 3

2° Les questions du Roi Milinda, traduit du pâli en cambodgien par le Vénérable Préas Uttama Muni Oum-Sou, Achar à la Bibliothèque Royale (suite)... 5

3° Dialogues entre sauterelle et garuda, morceau choisi, tiré du Paññâsajâtaka, et traduit par le Vénérable Préas Nhéan Bavarvichéa Em, Directeur de l'Ecole Supérieure de Pâli.............................. 21

4° Contes cambodgiens recueillis par E. Aymonier, II — Les trois hommes qui se disputent................ 37

**ILLUSTRATION :**

Maitreya au Musée de Saigon.......... 1




រូបព្រះអរិយមេត្រីយពោធិសត្វ នៅទីពិពិធភណ្ឌស្ថាន ក្រុងព្រៃនគរ

# អំពីរូបព្រះអរិយមេត្រីយពោធិសត្វ

នៅទីពិពិធភណ្ឌស្ថានក្រុងព្រៃនគរ


អ្នកស្រីស៊ុយសានការប៉ុឡេស អធិប្បាយ

ក្រម្ការដុំ-ម៉ៅ ប្រែជាភាសាខ្មែរ


## អំពីរូបព្រះអរិយមេត្រីយពោធិសត្វនៅក្នុងពិពិធភណ្ឌស្ថាន

ក្រុងព្រៃនគរ

ពិពិធភណ្ឌស្ថាន នៅក្រុងព្រៃនគរ មានរូបភាពខ្មែរខ្លះ ដែលមានប្រយោជន៍ បានមកអំពីខេត្តចាស់របស់ខ្មែរ ដែលសព្វថ្ងៃនេះ បានទៅជាខេត្តប៉ែកខាងទិសនិរតីនៃស្រុកកូសាំង-ស៊ីន. ក្នុងបណ្ដារូបភាពទាំងប៉ុន្មាននេះ ឃើញមានរូប ១ ដែលមានប្រយោជន៍ដោយឡែកផ្សេងដល់អស់លោកអ្នកទាំងឡាយ ដែលមើលទស្សនាវដ្ដីនេះ ព្រោះរូបភាពនេះឯងគេសាងដំណាងព្រះអរិយមេត្រីយពោធិសត្វ ។ តាមដែលសង្កេតមើលបែបយ៉ាងដែលគេសំរេចធ្វើជារូបនេះឡើង ដូចយ៉ាងរាងពៅ, សំលៀកនឹង

មុខ នោះគេអាចនឹងសំគាល់បានថារូបភាពនេះឯងកសាងឡើងក្នុងគ្រាដែលហៅថា សម័យ មុនអង្គរគឺក្នុងរវាង ព.ស. ១២០០ ទៅ ១៤៥០ ឆ្នាំ ។

ឯចេតីយដែលជាប់នៅមុខនោះ ធ្វើឲ្យយើងស្គាល់បានថាជារូបព្រះអរិយមេត្រីយពោធិសត្វ ព្រោះជាគ្រឿងសំរាប់សំគាល់ដោយឡែក ។ នៅក្នុងព្រះហស្តឆ្វេងប៉ែកខាងលើមានកាន់សៀវភៅ ហើយព្រះហស្តឆ្វេងខាងក្រោមច្រត់លើដំបង, ព្រះហស្តស្តាំខាងលើកាន់ច័ក្រ, ព្រះហស្តស្តាំខាងក្រោមកាន់ផ្កាចម្ប៉ាស្រទាប់សរបណ្តូលឈើង មានភាពសណ្ឋានប្រហែលនឹងដុំមូល ១ ។៚

# រឿងមិលិន្ទបញ្ហា

ព្រះឧត្តមមុនី អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា

## ប្រែពីបាឡីមកជាភាសាខ្មែរ

(១៤)

### កម្មនានាករណបញ្ហា ១ ទី ៤

ព្រះបរមក្សត្រាធិរាជ ស្ដេចទ្រង់ព្រះរាជបុច្ឆាបំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៤ ក្នុងវគ្គទី ៤ នេះតទៅទៀតថា បពិត្រព្រះថេរដ៏ចំរើន ខ្ញុំមានសេចក្ដីងឿងឆ្ងល់គិតមិនយល់មិនចូលចិត្តសោះ អំពីមនុស្សយើងសព្វថ្ងៃនេះ មិនដឹងជាហេតុអ្វីធម្មជាតិដូចម្ដេចធ្វើមនុស្សសត្វទាំងពួង ដែលកើតមកក្នុងលោកនេះ មិនឲ្យដូចគ្នា ស្មើគ្នាបាន ក៏បេះតែឲ្យផ្សេង ៗ គ្នា, ផ្លែកគ្នាទីទៃ ៗ ទៅដូចសេចក្ដីខាងក្រោយនេះ

"មានមនុស្សប្រុសស្រីបំពួកខ្លះ មានអាយុតិចឬអាយុខ្លី; មនុស្សប្រុសស្រីបំពួកខ្លះ មានអាយុច្រើនឬអាយុវែង; មនុស្ស

ប៉ែកខ្លះមានជម្ងឺដំកាត់ច្រើនក្នុងខ្លួនឬមានជម្ងឺជានិច្ចក្នុងរាងកាយមនុស្សប៉ែកខ្លះមានរោគាពាធតិចឬមិនសូវមានជម្ងឺដំកាត់ មនុស្សពួកខ្លះមានពណ៌សម្បុរអាប់អន់ ឬពណ៌អាក្រក់មិនជាទីបង់មើលបង់ឃើញដល់អ្នកដទៃ; មនុស្សពួកខ្លះមានពណ៌សម្បុរភ្លឺថ្លា ឬមានពណ៌សម្បុរស្រស់ស្អាតបាតគួរជាទីបង់មើលបង់ឃើញដល់ភ្នែកគេរាល់គ្នា; មនុស្សបំណែកខ្លះអាប់ឥតបុណ្យស័ក្តិ ឬជាមនុស្សមានអានុភាពតិច មិនសូវមានគេកោតខ្លាច; មនុស្សបំណែកខ្លះមានបុណ្យសក្តិធំថ្កុំថ្កើង និងមានសក្តានុភាពច្រើនប្រកបដោយយសបរិវារ; មនុស្ស ១ ផ្នែកទៀត ជាមនុស្សមានទ្រព្យសម្បត្តិតិចតួចស្តួចស្តើង ឬមិនសូវមានទ្រព្យ; មនុស្ស ១ ផ្នែកទៀត ជាអ្នកមានភោគសម្បត្តិច្រើនបរិបូណ៌ឥតមានខ្វះខាតឡើយ; មនុស្ស ១ ក្រុមទៀត ជាមនុស្សមានត្រកូលថោកទាបដុនដាប; មនុស្ស ១ ក្រុមទៀត ជាមនុស្សមានត្រកូលខ្ពង់ខ្ពស់ឧត្តុងឧត្តមរុងរឿង; មនុស្ស ១ ប៉ែកទៀត ជាមនុស្សអាប់ឥតប្រាជ្ញា ទាំងបំណេះវិជ្ជាក៏ពុំសូវមាន មនុស្ស ១ ប៉ែកទៀត ជាមនុស្សមានប្រាជ្ញាឈ្លៀវឈ្លាសវៀងវៃ ព្រមទាំងមានបំណេះវិជ្ជាផង." ឯមនុស្សទាំងអស់នេះ បើរាប់ជាគូពួកនោះត្រូវ ៧ គូ

បើរាប់រាយពួកត្រូវជា ១៤ ពួក ក៏មនុស្សទាំងនេះធម្មជាតិអ្វី តាក់តែងផ្តុំផ្តើមឲ្យកើតឡើង បានជាមិនដូចគ្នាមិនស្មើគ្នា នោះលោកម្ចាស់ សូមនិមន្តលោកម្ចាស់អត្ថាធិប្បាយបញ្ហានេះឲ្យប្រាស់លាស់មកមើល ។

គ្រានោះព្រះនាគសេនថេរ ថ្វាយព្រះពរទៅមហាក្សត្រវិញថា បពិត្រមហារាជ ប្រស្នាដែលទ្រង់ព្រះរាជបុច្ឆាមកនេះ ពីរោះពេកណាស់ ជាប្រស្នាដ៏ឧត្តមជាងប្រស្នាឯទៀតអាត្មាភាពបំរុងនឹងវិសជ្ជនាថ្វាយព្រះរាជសម្ភារមិនខាន តែមុនដែលនឹងវិសជ្ជនានោះ អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រសិន ថាវុក្ខាលតាជាតិព្រៃព្រឹក្សាទាំងឡាយ ដែលដុះឡើងចំរើនឡើង អំពីផែនដីតែម្យ៉ាងបុះហេតុអ្វីមិនដូចគ្នា ឈើខ្លះមានរសជូរ ខ្លះមានរសល្វីង ខ្លះមានរសហិល ខ្លះមានរសចត់ ខ្លះមានរសផ្អែម ផ្សេងគ្នាមិនដូចគ្នាមិនស្មើគ្នានោះតើធម្មជាតិអ្វី តាក់តែងឲ្យផ្សេងគ្នាមហារាជ សូមព្រះអង្គវិសជ្ជនាសេចក្តីនេះបន្តិចមកសិនមើល ។

ម. មញ្ញាមិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំសំគាល់ថាឈើទាំងឡាយបានជាមានរសផ្សេង ៗ គ្នានេះ មិនមែន

BIBLIOTHEQUE D'EXTREME ORIENT

ពីហេតុអ្វីទេគឺមកពីពូជដើមវាផ្សេង ៗ គ្នា ពូជឈើណាដែលជូរ វេលាដល់ជុំត ៗ ទៅ ក៏នៅតែឈើជូរដូចមុន ពូជឈើណាដែលផ្អែម គ្រាដល់ជុំត ៗ ទៅ ក៏នៅជាផ្អែមដូចពូជដើមនោះវិញ សូមលោកម្ចាស់ជ្រាបដោយប្រការយ៉ាងនេះ ។

៩. ឯវិមេរខោមហារាជ បពិត្រសម្តេចមហារាជឯរុក្ខជាតទាំងពួងបានជាមានរសផ្សេងគ្នា មិនដូចគ្នា ព្រោះពូជដើមវាផ្សេងគ្នាយ៉ាងណាមិញ ក៏មនុស្សប្រុសស្រីទាំងឡាយដែលមានអាយុខ្លីអាយុវែងមិនស្មើគ្នាជាដើម ក៏មិនគឺព្រោះហេតុអ្វី គឺមនុស្សទាំងនោះ បានសន្សំពូជគឺកុសលនឹងអកុសលទុកមកផ្សេង ៗ គ្នានោះឯង ទើបបានជាមនុស្សទាំងនោះមិនដូចគ្នា បពិត្រមហារាជ សេចក្តីនេះត្រូវគ្នានឹងពុទ្ធភាសិត ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទេសនា ប្រាប់ពួនឹងមាណពម្នាក់ថា៖ កម្មស្សកា មាណវ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធុ កម្មបដិសរណា កម្មំ សត្តេ វិភជ្ជតិ យទិទំ ហីនប្បណីតាយាតិ ។ ដូច្នេះជាប្រធានឥឡូវនេះអាត្មាភាពនឹងប្រែសេចក្តីក្នុងកម្មទាំង ៥ យ៉ាងនេះ ហើយនឹងអធិប្បាយថ្វាយមហាបពិត្រ តាមខ្សែពុទ្ធភាសិតនោះថា មាណវ ម្នាលមាណព សត្តា សត្វ

ទាំងឡាយ កម្មស្សកា មានកម្មជារបស់ខ្លួន កម្មទាយាទា គឺងត្រូវទទួលនូវផលនៃកម្ម កម្មយោនី មានកម្មជាកំណើត កម្មពន្ធុ មានកម្មជាផៅពង្ស កម្មបដិសរណា មានកម្មជាទីរលឹកតប បពិត្រមហារាជ កុសលកម្មនឹងអកុសលកម្មនេះជាមេចំណែកបែកសត្វឲ្យអាក្រក់ឲ្យល្អផ្សេងគ្នា ឥតមានអ្នកឯណាមានអំណាចអាចនឹងបែកសត្វទាំងនោះបានឡើយ ក្រៅពីកុសលនឹងអកុសលនេះ ។

ដែលថាកម្មស្សកានោះ សេចក្ដីថា សត្វទាំងឡាយឯណាបានធ្វើកុសលកម្ម ឬអកុសលកម្ម ដោយកាយ វាចា ចិត្ត របស់ខ្លួនហើយផលនៃកុសលកម្មឬអកុសលកម្មនោះ មិនដែលលះបង់ចោលម្ចាស់ដែលធ្វើនោះឡើយ នឹងត្រឡប់មកតាក់តែងឲ្យកើតជានាមនឹងរូប គឺជាខ្លួនប្រាណរបស់សត្វនោះវិញមិនខាន ហេតុនេះហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា កម្មស្សកា សត្វមានកម្មជារបស់ខ្លួន ៗ ធ្វើការងារល្អជាកុសល ក៏មានកេរ្តិ៍ឈ្មោះពីរោះផ្សាយទៅជាកល្យាណកិត្តិសព្ទ បើខ្លួនធ្វើការងារអាក្រក់ជាអកុសល ក៏មានកេរ្តិ៍ឈ្មោះមិនពីរោះផ្សាយទៅជាបាបកិត្តិសព្ទ ឯសេចក្ដីល្អនឹង

សេចក្ដីអាក្រក់នេះ ឥតមានអ្នកឯណា ១ នឹងនាំមកឲ្យខ្លួនឡើយ គឺខ្លួនឯងឲ្យឯងនោះឯង ។

កម្មទាយាទា ឋាសត្វទាំងឡាយ ត្រូវទទួលយកនូវផលនៃកុសលកម្ម ឬអកុសលកម្ម គឺផ្លែបុណ្យឬផ្លែបាប ដែលខ្លួនបានបណ្ដុះដាំទុកមករូបហើយជាពូជដើម. គឺឋាដែលខ្លួនបានធ្វើល្អឬអាក្រក់មកហើយនោះឯង កាលដើមខ្លួនធ្វើល្អ វេលាបានផល ។ នោះនាំឲ្យបំរើនល្អ, កាលដើមខ្លួនធ្វើអាក្រក់វេលាបានផល ។ នោះនាំឲ្យបំរើនអាក្រក់ ។

កម្មយោនី ឋាសត្វទាំងឡាយមានកុសលកម្ម នឹងអកុសលកម្មដែលខ្លួនបានសាងសន្សំទុកមកពីជាន់មុននោះ នាំឲ្យកើតក្នុងទុគ្គតិភពឬសុគតិភពមិនខាន កុសលកម្មឬអកុសលកម្មនេះហើយដែលជាអ្នកតាក់តែងជាតិ, តាក់តែងភព, តាក់តែងសម្បត្តិ, ទុកសម្រាប់ឲ្យសត្វដែលបានធ្វើនោះមិនដែលខានឥតមានធម្មជាតិឯណា ១ ក្រៅពីកុសលឬអកុសលនេះទៅតាក់តែងទុកឲ្យឡើយ ។

កម្មពន្ធូ ឋាសត្វទាំងឡាយមានកម្មគឺបុណ្យឬបាបដែលខ្លួនបានធ្វើហើយនោះ នឹងមកជាផៅពង្ស ជាញាតិ ជាមិត្រ

ជាបងប្អូនមិនខានឡើយ គឺថាបើខ្លួនធ្វើអំពើល្អ អ្នកដែលល្អ នឹងត្រូវការជាមួយនឹងខ្លួនផង បើខ្លួនធ្វើអាក្រក់ អ្នកដែលអា-ក្រក់នឹងត្រូវការជាមួយនឹងខ្លួនផង ធម្មតាសត្វទាំងឡាយតែប្រ-ព្រឹត្តធ្វើការនីមួយៗ ត្រូវគ្នាដូចគ្នាហើយ អ្នកទាំងនោះតែងតែចូលចិត្តរាប់អានគ្នាមិនខានព្រោះថាការងារត្រូវគ្នាដូចគ្នា ។

កម្មបដិសរណា ថាសត្វទាំងឡាយ មានការងារល្អឬអាក្រក់ជាទីរឭកតគ្នា ឬថាមានការងារល្អនឹងអាក្រក់ជាទីសំ-ណាក់អាស្រ័យ ឬថាជាគ្រូអាចារ្យជាធំជាងខ្លួន ព្រោះថាតែសត្វធ្វើការល្អហើយ ការនោះឯងតែងបង្គាប់សត្វ ឬនាំចិត្តសត្វឲ្យនឹកល្អឲ្យគិតល្អ បើសត្វធ្វើការអាក្រក់ហើយ. ការអាក្រក់នោះឯងតែងហៅតែងប្រើសត្វឲ្យនឹករក ឬរឭកទៅរកសេចក្ដីអាក្រក់នោះមិនខាន ព្រោះហេតុយ៉ាងហ្នឹងហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា កម្មបដិសរណា សត្វទាំងឡាយមានការងារជាទីរឭកគ្រប់ប្រាណ ។

មហារាជ បពិត្រសម្ដេចមហារាជ សេចក្ដីដែលអាត្មា-ភាពអធិប្បាយថ្វាយព្រះពរមកនេះ តាមខ្សែព្រះពុទ្ធភាសិត ដែលទ្រង់ទេសនាមកថា " សត្វដែលផ្សេងគ្នាមិនស្មើគ្នានោះ មិន

មែនពីព្រោះហេតុអ្វីឡើយ គឺពីព្រោះតែសត្វទាំងនោះប្រព្រឹត្ត ធ្វើអំពើខុះគ្នា សត្វពួកខ្លះចូលចិត្តចង់ធ្វើកុសល, ធ្វើបុណ្យ, ធ្វើល្អ. សត្វពួកខ្លះពេញចិត្តចង់ធ្វើអកុសលធ្វើបាបធ្វើអាក្រក់ (អំពើល្អ អាក្រក់) នេះហើយដែលជាអ្នកចែកបំណែកឲ្យសត្វ មិនស្មើគ្នា សត្វណាធ្វើល្អ បានបំណែកល្អគឺមានអាយុវែង មិនសូវមានរោគាពាធជាដើម សត្វណាធ្វើអាក្រក់ បានបំ-ណែកអាក្រក់គឺបានអាយុខ្លី មានរោគច្រើនជាដើម ប្រៀបដូច ដើមឈើទាំងឡាយដែលមានរសជាតិជូរចត់ផ្សេង ៗ គ្នា ព្រោះ តែពូជដើមផ្សេងគ្នានោះឯង សូមមហារាជ ជ្រាប ។

ម. កល្លោសិភន្តេ បពិត្រព្រះថេរដ៏ចំរើន លោកម្ចាស់ប៉ិន ប្រសប់ណាស់ បេះទាញយកពុទ្ធភាសិតមកសំដែងដោះប្រស្នា គួរឲ្យជាទីអស្ចារ្យពេកណាស់ ខ្ញុំចូលចិត្តអស់សង្ស័យហើយ ។

បដិកច្ចេវិភយាឧករណាបញ្ហា ១ ទី ៤

ព្រះបាទមិលិន្ទនរិន្ទរាជ ស្ដេចទ្រង់បុច្ឆាចំពោះទៅព្រះនាគ-សេនថេរក្នុងប្រស្នាទី៤នេះតទៅថា បពិត្រព្រះថេរដ៏ចំរើន ខ្ញុំ មានសេចក្ដីសង្ស័យនឹងពុទ្ធដីការបស់លោកម្ចាស់ ដែលពោល

នឹងខំពីកាលមុនថា អ្នកបួសក្នុងពុទ្ធសាសនាតែងនឹងធ្វើឲ្យរលត់នូវសេចក្តីទុក្ខក្នុងបច្ចុប្បន្ននេះ ដើម្បីនឹងមិនឲ្យទុក្ខដទៃកើតឡើងបាន ម្យ៉ាងទៀតថា អ្នកបួសនោះលោកតែងព្យាយាមបំបាត់ទុក្ខទាំងពួងជាមុន មិនឲ្យទុក្ខនោះកើតឡើងទាន់ បុះហេតុអ្វីក៏ចាំធ្វើដូច្នោះ បើប្រសិនណាបណ្តោយឲ្យទុក្ខទាំងនោះមកដល់ហើយ សឹមព្យាយាមរំលត់ទៅមិនបានឬដូចម្តេច លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារ ឯអ្នកបួសក្នុងព្រះពុទ្ធសានេះ កាលបើបណ្តោយឲ្យសេចក្តីទុក្ខមកដល់ហើយទើបធ្វើព្យាយាមរំលត់នោះ ការព្យាយាមនោះមិនមែនជាកិច្ចត្រូវធ្វើឡើយ ឯការដែលនឹងរំលត់ទុក្ខនោះត្រូវធ្វើព្យាយាមទុកជាមុនទើបគួរជាកិច្ចត្រូវធ្វើ ។

ម. ឧបមំករោហិ សូមលោកម្ចាស់ប្រៀបប្រាយសេចក្តីនោះយ៉ាងខ្លីបន្តិចមកនឹងស្តាប់មើល ។

ន. តំកឹមញ្ញសិ មហារាជ បពិត្រសម្តេចមហារាជ បុះព្រះរាជសម្ភារ ស្តេចទ្រង់ព្រះរាជដំរិះសំគាល់នូវហេតុនោះថាដូចម្តេច រឿងនេះអាត្មាភាពសូមប្រៀបជាសេចក្តីថ្វាយថាដូចជា

អង្គរបស់មហាបពិត្រ ប្រសិនណាបើជាព្រះអង្គមានសេចក្ដីស្រែកនូវព្រះឧទករស ក្នុងវេលាណា ១ ហើយទើបនឹងទ្រង់ចាត់ចែងឲ្យមនុស្សទាំងឡាយក៏កាយជីកនូវអណ្ដូង ឬស្រះបោក្ខរណីដើម្បីដកល់ទុកនូវទឹកសម្រាប់សោយ រួចហើយទើបនឹងតាំងព្រះរាជហឫទ័យថា អាត្មាអញនឹងរកទឹកផឹកដូច្នេះ ក្នុងវេលានោះឬអ្វីមហារាជ ។

ម. នហិភន្តេ បពិត្រព្រះបេរដ៏ចំរើន មិនមែនដូច្នោះទេ ឯទឹកនោះយើងត្រូវធ្វើទីកន្លែងសម្រាប់ដកល់ទុកជាមុន ឲ្យមាននៅជានិច្ចសម្រាប់ផឹក តែនឹកបង់ផឹកវេលាណាក៏ផឹកក្នុងវេលានោះភ្លាមទៅ មិនមែនធ្វេសប្រហែសបណ្ដែតបណ្ដោយឲ្យដល់ពេលស្រេកឃ្លាន ហើយទើបនឹងចាត់ចែងឲ្យគេជីកអណ្ដូងឬ-ស្រះដូច្នោះទេលោកម្ចាស់ ។

ន. ឯវមេវខោមហារាជ បពិត្រព្រះបរមរាជាធិរាជថាចំ-ណែកអស់លោកអ្នកបួសក្នុងព្រះពុទ្ធសាសនា ដែលខំព្យាយាមរំលតនូវសេចក្ដីទុក្ខជាមុននោះក៏ដូច្នោះដែរ ឯសេចក្ដីទុក្ខនេះលុះតែខំព្យាយាមប្រឹងប្រែងគេចវេះចេញអំពីចំងាយជាមុនទើបបានរួចខ្លះហើយគួរជាកិច្ចត្រូវធ្វើផង បើបង្អង់ទុកឲ្យសេចក្ដីទុក្ខ

ក្លូលមកជិតឬមកដល់ហើយ ទើបព្យាយាមតទល់នឹងសេចក្ដីទុក្ខនេះមុខជាមិនអាចនឹងតទល់បានឡើយ អំពើដែលខំធ្វើនោះក៏នឹងនាំឲ្យគ្រាន់តែហត់នឿយឥតប្រយោជ ហើយមិនមែនជាកិច្ចត្រូវធ្វើផង ។

ម. សូមលោកម្ចាស់ ឧបមាឲ្យផ្សេងពីនេះតទៅទៀតមើលព្រះបើរ ។

ន. តំកំបញ្ញាសិមហារាជ បពិត្រព្រះរាជសម្ភារបុះបហាបពិត្រស្ដេចជ្រាបនូវរឿងនេះដូចម្ដេចទៅ ឯអាត្មាភាពសូមប្រៀបសេចក្ដីនេះថ្វាយថា ដូចជាអង្គមហារាជ ប្រសិនណាបើស្ដេចមានសេចក្ដីស្រេកឃ្លាននូវក្រយាស្ងោយយ៉ាងខ្លាំងឡើងក្នុងព្រះកាយក្នុងគ្រាណា ១ ហើយព្រះអង្គទើបនឹងត្រាស់បង្គាប់ឲ្យមនុស្សទាំងពួងភ្ជួរស្រែ ឲ្យព្រោះស្រូវខ្វាយឬដំណើប ហើយទើបដឹកនាំនូវស្រូវនោះមក រួចទើបទ្រង់តាំងព្រះរាជហឫទ័យថា អាត្មាអញនឹងបរិភោគនូវបាយដូច្នេះក្នុងគ្រានោះឬអ្វីមហាបពិត្រ ។

ម. នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែនដូច្នោះទេ ឯភោជនាហារនោះ យើងត្រូវបង្គាប់ឲ្យពួកវិសេសគេបាត់

បែងទុកប្រចាំពេលរាល់ពេល តែឃ្លានវេលាណានឹងបរិភោគក្នុងវេលានោះ មិនបាច់ចាំបង្គាប់ឲ្យភ្ញាស្រែនោះឡើយ ។

ន. ឯវមេវខោមហារាជ បពិត្រមហារាជ សេចក្ដីនេះប្រៀបដូចការព្យាយាម រំលត់ទុក្ខរបស់លោកអ្នកបួសក្នុងពេលដែលទុក្ខមកដល់ហើយ ទើបខំព្យាយាមនោះមិនអាចរំលត់បានឡើយ ហើយមិនមែនជាកិច្ចការត្រូវប្រែកបផង គួរតែព្យាយាមបំរុងទុកជាមុនទើបគួរជាកិច្ចត្រូវធ្វើ ប្រៀបដូចជាអ្នកដែលត្រូវបរិភោគនូវភោជនាហារ គួរតែចាត់បែងអាហារនោះបំរុងទុកជាមុន តែឃ្លានវេលាណា ក៏នឹងទទួលទានក្នុងវេលានោះទើបមិនលំបាក ។

ម. ភិយ្យោឧបមំករោហិ សូមលោកម្ចាស់ឧបមាឲ្យច្រើនទៀតមើល ។

ន. តំកិំមញ្ញសិ មហារាជ បពិត្រមហារាជ ចុះមហាបពិត្រស្ដេចជ្រាបនូវហេតុនោះថាយ៉ាងណា អាត្មាភាពសូមថ្វាយព្រះពរថា ប្រៀបដូចអង្គមហារាជប្រសិនណាបើមានសឹកសង្គ្រាមគេលើកមកដល់ជិតព្រះអង្គហើយក្នុងវេលាណា បំ-

ណែកព្រះអង្គទើបនឹងចាត់ចែង ឲ្យដីកគូស្នាមភ្លស់ពាត់ជុំព្រះ-រាជវាំង ឲ្យធ្វើកំពែងបិទបាំងអំពីខាងក្នុង ឲ្យរាំងបាំងទ្វារស្រុកឲ្យធ្វើបន្ទាយ ហើយដឹកនាំនូវស្បៀងទុកបំរុងបរិភោគ ហើយទើបនឹងចាត់ការឲ្យបង្ហាត់ពលដំរី, ពលសេះ, ពលរទេះ, ពលធ្នូ, ពលដាវលំពែង ក្នុងពេលដែលសង្គ្រាមគេមកដល់នោះ ឬអ្វីព្រះអង្គ ។

ម. នហិភន្តេ បពិត្រលោកម្ចាស់ដ៏បំរើន មិនមែនដូច្នោះទេឯកិច្ចការដែលត្រូវរក្សានូវព្រះនគរនោះ យើងត្រូវប្រុងប្រយត្នចាត់ការទុកជាមុនពីចំងាយជាស្រេច តែបង្អង់ទុកឲ្យសត្រូវមកដល់ហើយទើបចាត់ការ ៗ នោះមិនអាចសំរេចទៅបានឡើយ ។

ន. ឯវមេវខោមហារាជ បពិត្រព្រះរាជសម្ភារ ឯអ្នកបួសក្នុងពុទ្ធសាសនា ថាបើបណ្តែតបណ្តោយឲ្យសេចក្តីទុក្ខនោះបួលមកដល់ហើយទើបព្យាយាមរំលត់ទុក្ខនោះ សេចក្តីព្យាយាមនោះមិនមានប្រយោជន៍ឡើយ លុះតែព្យាយាមបំរុងទុកជាមុនទើបជាកិច្ចគួរគាប្បីប្រកប បពិត្រព្រះរាជសម្ភារ សេចក្តីនេះដូចគ្នានិងភាសិតរបស់ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាទុកមកថាៈ

BIBLIOTHÈQUE ...ÇAISE D'EXTRÊME ORIENT

បដិកច្ចេវតំកយិរា យំជញ្ញាហិតមត្តនោ
(១)
នសាកដិកចិន្តាយ មន្តាធីរោបរក្កមេ
យថាបិសាកដិកោនាម បត្ថំសមំហិត្វាមហាបថំ
វិសមំមគ្គមារុយ្ហ អក្ខច្ឆិន្នោវឈាយតិ
ឯវំធម្មាអបក្កម្ម អធម្មមនុវត្តិយ
មន្ទោមច្ចុមុខំបត្តោ អក្ខច្ឆិន្នោវឈាយតីតិ

(ប្រែជាសេចក្ដីថា) ធម្មតាអ្នកប្រាជ្ញដែលមានប្រាជ្ញា មានបំណោះបេះដឹងច្រើន ជាអ្នកមានព្យាយាម លោកតែងដឹងនូវកិច្ចឯណាដែលជាប្រយោជន៍របស់ខ្លួនហើយ ក៏តែងធ្វើនូវកិច្ចជាប្រយោជន៍នោះឲ្យស្រេចជាមុនមិនខាន មិនបានធ្វើតាមគំនិតនៃអ្នកឈ្មួញរទេះនោះឡើយ ឯអ្នកឈ្មួញរទេះខ្លះដែលល្ងង់តែងលះបង់ចោលនូវផ្លូវធំដែលរាបស្មើល្អនោះចេញ ហើយបររទេះរបស់ខ្លួនទៅតាមផ្លូវតូចដែលមានដង្ហុកត្កុកច្រើនមិនបានរាបស្មើ ឯរទេះនោះក៏បាក់ភ្លៅវិនាសទៅ ចំណែកម្ចាស់រទេះក៏

១ ក្នុងសៀវភៅមិលិន្ទបញ្ហាប្រែថា “នបសាកដិចិន្តេន” មិលិន្ទបញ្ហាបាលីថា “នសាកដិកចិន្តាយ” ដូចក្នុងទីនេះ ។

កើតទោមនស្សតូចចិត្តនៅក្នុងទីនោះយ៉ាងណាមិញ ក៏ធម្មតាបុគ្គលដែលជាអ្នកល្ងង់ខ្លៅអប្បឥតប្រាជ្ញាតែងគេចចៀសវាងចាកធម៌ដែលត្រូវដែលល្អនោះចេញ ទំប្រព្រឹត្តធ្វើតាមនូវធម៌ដែលខុសដែលលាមកនោះវិញ វេលាសេចក្តីស្លាប់មកដល់ហើយក៏តក់ស្លុតវង្វេងស្មារតីទៅក្នុងគ្រានោះ ប្រៀបដូចជាអ្នកម្ចាស់រទេះដែលមានរទេះបាក់ភ្លោះជិតនៅក្នុងផ្លូវនោះឯង ។

ម. កណ្ហេសិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើនលោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់ បេះវិសជ្ជនាពីរោះក្បស់ក្បាយគួរឲ្យចូលចិត្តណាស់ខ្ញុំអស់សង្ស័យហើយ ។

(មានតទៅទៀត)

# ប្រស្នាជម៉

ព្រះញាណបវរវិជ្ជា អែម ចាងហ្វាងសាលាបាលីជាន់ខ្ពស់នៅក្រុងភ្នំពេញ

រៀបរៀង

— ២ —

## ប្រស្នាសត្តកណ្តាបនឹងគ្រុឌ[១]

ទី ២. ប្រស្នាសត្តកណ្តាបនឹងសត្តគ្រុឌ

រឿងនេះតគ្នាពីរឿងមុន សម្តែងសេចក្តីថា សម័យនោះភិក្ខុទាំងឡាយបបួលគ្នាទៅប្រជុំក្នុងរោងធម្មសភា ហើយពោលសរសើរបញ្ញាបារមីព្រះសម្មាសម្ពុទ្ធថា អាវុសោ ម្នាល-អ្នកទាំងឡាយដ៏មានអាយុ ព្រះតថាគតជាម្ចាស់នៃយើងទាំងឡាយ មហាបញ្ញោ ព្រះអង្គមានប្រាជ្ញាច្រើន បុថុ-បញ្ញោ ព្រះអង្គមានបញ្ញាក្រាសដូចជាផែនដី តិក្ខបញ្ញោ ព្រះ-អង្គមានបញ្ញាដ៏មុតដូចខ្វែនប្លា គម្ភីរបញ្ញោ ព្រះអង្គមានបញ្ញា

---

១ ពាក្យនេះ ភាសាបាលីថា គរុឡ គរុឡស័ព្ទនេះប្រែថាសត្វគ្រុឌក៏បាន សត្វសសេះក៏បាន ។

ជ្រាលជ្រៅដូចទឹកសមុទ្ទ ជវនបញ្ញោ ព្រះអង្គមានបញ្ញាដ៏រហាស់រៀងរៃ ហាសបញ្ញោ ព្រះអង្គមានបញ្ញាញ៉ាំងលោកនេះព្រមទាំងទេវលោកឲ្យស្រើបស្រួលបាន និព្វេធិកបញ្ញោ ព្រះអង្គមានបញ្ញាពុំបានជឿងធ្វល់នឹងបញ្ញាអ្វីដ៏ហោចទៅ ល្មម្បីតែបញ្ហាសត្តតិរច្ឆាន ក៏ព្រះអង្គអាចជ្រាបច្បាស់ពុំមានសេសសល់ ព្រះអង្គអាចដោះស្រាយបញ្ហាព្យាករណ៍ដ៏ពីរោះពេកគួរយើងទាំងឡាយគប្បីស្តាប់ណាស់ អហោវត តថាគតោ មហាបញ្ញោ ឱហ្ន៎ព្រះតថាគតជាម្ចាស់យើង ព្រះអង្គមានបញ្ញាអ្វីច្រើនដល់ម្លេះ ៗ

ពាក្យដែលភិក្ខុទាំងឡាយពោលសរសើរ គុណព្រះអង្គនោះពុំបាត់ស្ងាត់ឡើយ បានជ្រាបទៅដល់ព្រះស្រោតទិព្វថ្លៃនៃព្រះអង្គហើយទ្រង់យាងទៅ កាន់ទីប្រជុំនៃភិក្ខុទាំងឡាយសួរពាំងមាននោះបានជ្រាបសព្វគ្រប់ហើយ ទើបព្រះអង្គមានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតមានប្រាជ្ញាអាចដោះប្រស្នាសត្តតិរច្ឆានបាន មិនតែក្នុងកាលឥឡូវនេះទេ ព្រះតថាគតមានប្រាជ្ញា អាចដោះប្រស្នាសត្តតិរច្ឆានបានតាំងតែពី

ក្នុងកាលមុនមក ព្រះអង្គសំដែងជួច្នេះហើយ ទ្រង់គង់ស្ងៀមនៅដោយតុណ្ហីភាព ។

ភិក្ខុទាំងឡាយក៏បានអារាធនានិមន្តព្រះអង្គ ឲ្យនាំអតីតនិទានមកសម្ដែង ដើម្បីនឹងបានស្ដាប់ដឹងសេចក្ដីរាល់គ្នា ។

ឯអង្គសម្ដេចព្រះលោកុត្តមាចារ្យជាម្ចាស់ ព្រះអង្គបានទទួលអារាធនានិមន្តព្រះភិក្ខុសង្ឃទាំងឡាយ ហើយទ្រង់នាំអតីតនិទានមកសម្ដែងថា ម្នាលភិក្ខុទាំងឡាយ នាកាលអតីតកាលកន្លងរំលងទៅយូរណាស់ហើយ មានស្ដេច ១ ព្រះអង្គទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ។

គ្រានោះព្រះបរមៈពោធិសត្វ បានអង្គោលទៅកើតក្នុងត្រកូលនៃកុដុម្ពីក៏ដ៏ជាធំ លុះដល់ចំរើនវ័យធំឡើងៈហើយ អំណើសផុតអំពីមាតាបិតាទៅ សម្បត្តិទ្រព្យទាំងប៉ុន្មានបានមកព្រះបរមពោធិសត្វទាំងអស់ ។

ឯពោធិសត្វនោះក៏គិតថា អញនឹងរៀនវិទានហោង នឹងទៅកាន់ស្ថានសួគ៌ គិតស្រេចហើយក៏បរិច្ចាគទ្រព្យទាំងអស់ឲ្យទៅជាទានដល់ស្មូមយាចកអ្នកកំសត់ទុគ៌តទាំងឡាយ នៅ

សល់ប៉ុន្មានណាបែងសម្បត្តិនោះជាពីរចំណែក ចំណែកមួយថ្វាយទៅព្រះមហាក្សត្រ ចំណែក ១ ទៀតឲ្យទៅដល់ពពួកញាតិទាំងឡាយរបស់ខ្លួន ហើយចេញទៅបួស ជាតាបសឫសីនៅអាស្រ័យក្នុងអស្រមបទប្រទេសព្រៃហេមពាន្ត ចិញ្ចឹមជីវិតរស់នៅដោយមើមឈើ នឹងផ្លែឈើ ហើយបានធ្វើនូវកសិណរាបរិកម្មចំរើនបាននូវឈានសមាបត្តិស្ទាត់ ក៏នៅអាស្រ័យក្នុងទីនោះអស់កាលយូរ ។

គ្រានោះមានដើមជ្រៃធំ ១ នៅជាខាងកើតនៃអស្រមបទនោះ មានសត្វកណ្ដុបធំ ១ មានសរីរាង្គធំប្រមាណប៉ុនផ្លែល្ពៅ នៅអាស្រ័យនឹងដើមជ្រៃនោះជាប្រក្រតី ។

កាលនោះ មានសត្វគ្រុឌធំ ១ ហើរចេញទៅអំពីព្រៃហេមពាន្ត ត្រាច់ទៅរកចំណីអាហារសព្វទិសទាំងពួងរកអាហារពុំបាន ហើយក៏ហើរមកទំលើដើមជ្រៃធំនោះក្រលេកមើលទៅបានឃើញសត្វកណ្ដុបធំទំនៅមែកជ្រៃនោះហើយ គ្រុឌគិតថា៖ « ឱហ្ន៎អាហារអញបានហើយតើ » ទើបគ្រុឌនោះបានពោលបំពោះទៅនឹងសត្វកណ្ដុបធំថា « សលភ ម្នាលសត្វកណ្ដុបអញនឹងស៊ីអ្នកឯង ឥឡូវនេះ » ។

បំណែកឯសត្វកណ្ដុបធំ បានឮសំឡេងគ្រុឌហើយភិតភ័យរន្ធត់ញាប់ញ័រសព្វសារពាង្គរាងកាយ ខំរិះគិតស្វែងរកឧ-បាយនឹងដោះខ្លួនឲ្យរួចពីមរណៈដោយគំនិតថា "អញនឹងធ្វើនូវឧបាយដូចម្ដេច ដ្បិតសត្វគ្រុឌនេះមានកំឡាំងខ្លាំងពេកណាស់ នឹងបរិភោគស៊ីអញជាចំណីវា ជីវិតរបស់អញមុខជានឹងមិនមានក្នុងកាលតទៅនេះ" ។ សត្វកណ្ដុបធំគិតដូច្នេះហើយ បានពោលទៅនឹងសត្វគ្រុឌនោះថា ភោះហាគរុឡ(១) ម្នាលសត្វគ្រុឌធំដ៏ចំរើន អ្នកឯងពេះអ្វីបានជាអ្នកឯងគិតស៊ីអញជាចំណីឯង ។

កាលនោះសត្វគ្រុឌធំបានពោលទៅនឹងសត្វកណ្ដុបវិញថា "អ្នកឯងពេះដឹងអ្វី" ។

សត្វកណ្ដុបធំពោលថា "ម្នាលសត្វគ្រុឌ អញនេះជាបុគ្គលឆ្លាសពេះដឹងណាស់" ។

សត្វគ្រុឌពោលថា "ម្នាលសត្វកណ្ដុប ថាបើអ្នកឯងពេះដឹងណាស់ ត្រូវអ្នកឯងពោលមកនឹងអញបុះ អញនឹងស្ដាប់ផងមើល" ។

---

១ ស័ព្ទថា គរុឡនេះ ប្រែថា សត្វគ្រុឌក៏បាន ថា សត្វសសេះក៏បាន ។

សត្វកណ្ដុបធំបានពោលតបទៅវិញថា "ម្នាលគ្រុឌអញនឹងសួរបញ្ហាទាំងឡាយ ៤ ចំពូកនឹងអ្នកឯង ថាបើអ្នកឯងចេះដឹងមែន ដោះប្រស្នាអញរួច ទើបអ្នកឯងស៊ីអញជាចំណីបានស្រួលល្អ ថាបើអ្នកឯងមិនចេះដឹងអ្វីទេហើយស៊ីអញជាចំណីអ្នកឯង ក្បាលអ្នកឯងនឹងបែកជាប្រាំពីរភាគពុំខាន ។

សត្វគ្រុឌស្ដាប់ហើយពោលថា "ម្នាលសត្វកណ្ដុបធំ អ្នកឯងចូរសួរបញ្ហានោះមកចុះ អញនឹងឆ្លើយតបឥឡូវនេះ" ។

សត្វកណ្ដុបនោះក៏សួរបញ្ហាចំពោះទៅនឹងសត្វគ្រុឌថា "ម្នាលសត្វគ្រុឌ សភាវតែ ១ ឈ្មោះថារុងរឿងល្អក្រៃលែងជាងសភាវឯទៀតគឺសភាវអ្វី" ។

ឯសត្វគ្រុឌឆ្លើយថា "ព្រះចន្ទរះឡើងក្នុងថ្ងៃ ១៥ កើតនេះឈ្មោះថាល្អក្រៃលែង" ។

ចំណែកឯសត្វកណ្ដុបស្ដាប់ហើយពោលថា "ម្នាលសត្វគ្រុឌដ៏ចំរើន ព្រះចន្ទរះឡើងក្នុងថ្ងៃ ១៥ កើតល្អបានតែក្នុងលោកពុំបានល្អក្នុងខ្លួនឡើយ សភាវដទៃដែលល្អក្នុងខ្លួន អ្នកឯងពុំបានដឹងនូវអត្ថកថា, ពុំបានដឹងនូវសេចក្ដីអធិប្បាយឡើយ ។

ម្នាលសត្វក្រុឧដ៏ចំរើន សភាវៈតែមួយដ៏ល្អិតសុខុម ក្រៃលែងជាងសភាវឯទៀតគឺសភាវអ្វី" ។

បំណែកខាងសត្វក្រុឧឆ្លើយតបថា "ម្នាលសត្វកណ្ដូបធំដ៏ចំរើន ឯសភាវល្អិតដ៏សុខុមក្រៃលែង មានតែសំឡីក្របាសជាសភាវល្អិតម៉ត់គឺបុគ្គលថ្លឹងពុំបាន" ។

សត្វកណ្ដូបស្ដាប់ហើយពោលថា "ម្នាលសត្វក្រុឧដ៏ចំរើន ឯសំឡីក្របាសល្អិតម៉ត់ថ្លឹងពុំបានមានតែក្នុងលោកពុំមានក្នុងខ្លួនឡើយ ឯសភាវល្អិតម៉ត់ដែលមានក្នុងខ្លួនអ្នកឯងពុំបានដឹងនូវអដ្ឋកថា ពុំបានដឹងនូវសេចក្ដីអធិប្បាយឡើយ ។ ម្នាលសត្វក្រុឧដ៏ចំរើន សភាវតែមួយដ៏វែងពិត ក្រៃលែងជាងសភាវឯទៀតគឺសភាវអ្វី" ។

សត្វក្រុឧស្ដាប់ហើយឆ្លើយតបថា "ម្នាលសត្វកណ្ដូបធំឯវែងក្រៃលែងនោះមានតែផ្លូវ ជនទាំងឡាយដើរទៅក្នុងមួយថ្ងៃ ៗ ពុំចេះផុត ផ្លូវនេះឈ្មោះថាសភាវវែងក្រៃលែងវែង" ។

សត្វកណ្ដូបស្ដាប់ហើយពោលថា "ម្នាលសត្វក្រុឧដ៏ចំរើន អ្នកឯងពុំបានដឹងនូវអដ្ឋកថា ពុំបានដឹងនូវសេចក្ដីអធិ-

ប្បាយឡើយ ម្នាលសត្វគ្រុឌដ៏ចំរើន សភាវតែមួយពុំមាន ហើយពុំមានក្រៃលែងជាងសភាវឯទៀតគឺសភាវអ្វី " ។

សត្វគ្រុឌស្តាប់ហើយឆ្លើយតបថា " ម្នាលសត្វកណ្តុបធំ ឯមរណធម៌នេះឈ្មោះថាខ្យល់ដកដង្ហើមចេញនៃសត្វលោកទាំងឡាយ បានឈ្មោះថាសភាវពុំមានហើយពុំមានដ៏ក្រៃលែង " ។

គ្រានោះសត្វកណ្តុបធំបានស្តាប់ហើយពោលថា " ម្នាលសត្វគ្រុឌដ៏ចំរើន អ្នកឯងពុំបានដឹងនូវអដ្ឋកថា ពុំបានដឹងនូវសេចក្តីអធិប្បាយឡើយ បណ្តាបញ្ហាទាំង ៤ នេះ សូម្បីតែបញ្ហាមួយក៏អ្នកឯងពុំបានដឹងសោះ បើអ្នកឯងស៊ីអញ ក្បាលអ្នកឯងនឹងបែកជា ៧ ភាគ ថាបើអ្នកឯងប្រាថ្នានឹងស៊ីអញ មានតែយើងទាំងឡាយទៅកាន់សំណាក់តាបសឫសី ហើយសួរសេចក្តីអធិប្បាយប្រស្នានេះសិន បើតាបសឫសីបានព្យាករណ៍ដោះស្រាយប្រស្នានេះហើយ ពាក្យអ្នកឯងសមគួរមែន ទើបអ្នកឯងស៊ីអញបានដោយស្រួល ។

គ្រានោះសត្វគ្រុឌពោលថា " ម្នាលកណ្តុបពាក្យអ្នកឯងពោលមកប្រពៃហើយ អញនឹងទៅឥឡូវនេះ គ្រុឌពោលដូច្នេះ

ហើយក៏ហើរឡើងតាមអាកាស ចូលទៅកាន់សំណាក់ឫសី ថ្វាយបង្គំហើយឈរនៅទីដ៏សមគួរមួយ ។

ឯសត្វកណ្ដុបក៏ហើរឡើងតាមអាកាស ចូលទៅកាន់សំណាក់តាបសឫសី ថ្វាយបង្គំហើយក៏ឈរនៅក្នុងទីសមគួរមួយ ដល់កណ្ដុបនោះឈរនៅក្នុងទីដ៏សមគួរស្រេចហើយ ក៏ពោលនូវពាក្យបដិសណ្ឋារស្រួលបួលទៅនឹងតាបសឫសីថា "ភន្តេបពិត្រលោកដ៏ចំរើន កច្ចិ ខមនិយំ យន្តគឺសរីរាងកាយមានទ្វារ ៩ មានចក្រ ៤ គួរគឺលោកគាប្បីអត់សង្កត់បានខ្លះដែរឬ កច្ចិយាបនិយំ យន្តគឺសរីរមានទ្វារ ៩ មានចក្រ ៤ គួរគឺលោកគប្បីឲ្យប្រព្រឹត្តទៅបានដោយស្រួលទេឬ ។

តាបសឫសីស្ដាប់ហើយថា "ម្នាលកណ្ដុបធំដ៏ចំរើន កច្ចិយាបនិយំ យន្តគឺសរីរមានទ្វារ ៩ មានចក្រ ៤ គឺអាត្មាគាប្បីឲ្យប្រព្រឹត្តទៅបានស្រួលខ្លះដែរ អហោ ខមនិយំ ម្យ៉ាងវិញទៀត យន្តគឺសរីរមានទ្វារ ៩ មានចក្រ ៤ គឺអាត្មាគាប្បីអត់សង្កត់បានដោយស្រួលទេ ។

ចំណែកខាងសត្វកណ្ដុប បានស្ដាប់ហើយក៏ពោលថា "បពិត្រលោកម្ចាស់ដ៏ចំរើន គ្រុឌនេះគិតនឹងស៊ីខ្ញុំជាចំណីអា-

ហាវរ៉ា ខ្ញុំក៏បានសួរនូវប្រស្នាទាំងឡាយ ៤ បំពូក ទៅនឹងសត្វក្រុឧនេះ ឯសត្វក្រុឧនេះសូម្បីតែប្រស្នាមួយក៏ពុំដឹង ឥឡូវនេះយើងទាំង ២ អ្នកបានចូលមកកាន់សំណាក់លោកម្ចាស់ សូមលោកជាម្ចាស់ដោះស្រាយនូវសេចក្តីអធិប្បាយនៃប្រស្នានេះដល់យើងទាំងឡាយ" ។

តាបសឫសីពោលថា "ម្នាលសត្វកណ្តុបធំដ៏ចំរើន អ្នកឯងពោលនូវប្រស្នាទាំងឡាយ ៤ នោះដូចម្តេច ចូរអ្នកឯងពោលមកមើល" ។

សត្វកណ្តុបពោលថា "ភន្តេ បពិត្រលោកដ៏ចំរើនខ្ញុំម្ចាស់បានសួរប្រស្នានឹងក្រុឧនេះថា សភាវតែមួយឈ្មោះថារុងរឿងល្អក្រៃលែងជាងសភាវឯទៀតគឺសភាវអ្វី ឯសត្វក្រុឧនេះឆ្លើយថា ព្រះចន្ទពេញបូណ៌មី ឈ្មោះថារុងរឿងល្អដ៏ក្រៃលែង" ។

តាបសឫសីសួរក្រុឧថា ពាក្យនេះអ្នកឯងពោលពិតមែនឬ

ក្រុឧពោលថា បពិត្រលោកដ៏ចំរើន ពាក្យនេះខ្ញុំម្ចាស់បានពោលពិតមែន ។

តាបសឫសី ពោលថាអ្នកឯងពុំបានដឹងប្រស្នានេះមែនហើយឫសីព្យាករណ៍ដោះប្រស្នានេះថា ម្នាលសត្វក្រុឧ សីល

៥ ក្តី, សីល ៨ ក្តី, សីល ១០ ក្តី, មានដល់មនុស្សទាំងឡាយឯណា មនុស្សទាំងឡាយនោះឈ្មោះថារុងរឿងល្អដ៏ក្រៃលែងដោយវិសេសក្នុងលោក ។

កណ្ឌបស្តាប់ហើយ ឲ្យសាធុការថាសាធុ ៗ ហើយពោលថា បពិត្រលោកដ៏ចំរើន ខ្ញុំម្ចាស់បានសួរប្រស្នា ១ ទៀតថា សភាវតែមួយដ៏ល្អិតម៉ត់សុខុម ក្រៃលែងជាងសភាវឯទៀតគឺសភាវអ្វី គ្រុឌនោះឆ្លើយតបថា សំឡីក្របាសជាសភាវល្អិតម៉ត់ដ៏សុខុមក្រៃលែងគឺបុគ្គលថ្លៃងពុំបាន ។

តាបសប្ញសីសួរថា ម្នាលគ្រុឌ ពាក្យនេះអ្នកឯងពោលពិតមែនឬ ។

គ្រុឌពោលថា ពាក្យនេះខ្ញុំម្ចាស់បានពោលពិតមែន ។

តាបសប្ញសីពោលថា តុំសុណោសិ អ្នកឯងស្តាប់ពាក្យអាត្មាចុះ ឯសភាវល្អិតម៉ត់ដ៏សុខុមក្រៃលែងនោះ គឺលោកុត្តរធម៌ទាំង ៩ បំរួក ព្រមទាំងព្រះបរិយត្តិធម៌ មានន័យផ្សេង ៗ ឈ្មោះថាសភាវល្អិតម៉ត់ដ៏សុខុមក្រៃលែង ។

កណ្ឌបស្តាប់ហើយឲ្យសាធុការថាសាធុ ៗ ហើយទូលថា បពិត្រលោកដ៏ចំរើន ខ្ញុំម្ចាស់បានសួរប្រស្នា ១ ទៀតថា សភាវ

តែ ១ វែងឆ្ងាយ ដ៏ក្រៃលែងជាងសភាវឯទៀតគឺសភាវអ្វី គ្រុឌ
នេះឆ្លើយតបថា ផ្លូវដែលមនុស្សទាំងឡាយត្រេចទៅសព្វថ្ងៃ
ឈ្មោះថាសភាវវែងឆ្ងាយដ៏ក្រៃលែង ។

តាបសឫសីសួរគ្រុឌវិញថា ម្នាលគ្រុឌ ពាក្យនេះអ្នកឯង
បានពោលមែនឬ ។

គ្រុឌឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំម្ចាស់បានពោល
មែន ។

តាបសឫសីស្ដាប់ហើយពោលថា ម្នាលគ្រុឌដ៏ចំរើន អ្នក
ឯងពុំដឹងមែន អ្នកឯងត្រូវស្ដាប់ពាក្យអាត្មាវិញ ធម៌ទាំងឡាយ
ពីរគឺសប្បុរិសធម៌នឹងអសប្បុរិសធម៌ ទើបឈ្មោះថាវែងឆ្ងាយអំពី
គ្នានឹងគ្នាដ៏ក្រៃលែង ត្រើយសមុទ្រឈ្មោះថាឆ្ងាយដោយវិសេស
អំពីសមុទ្រ, ផែនដីឈ្មោះថាឆ្ងាយដោយវិសេសអំពីអាកាស,
១ រយគុណ ១ ពាន់គុណ ១ ភ្នំគុណ ១ សែនគុណ អ្នកឯង
ពោលថាផ្លូវឆ្ងាយដោយវិសេសនោះខុសទេគ្រុឌ ។

កណ្ដុបស្ដាប់ហើយឲ្យសាធុការថាសាធុ ៗ ហើយទូល
ថាបពិត្រតាបសដ៏ចំរើន ខ្ញុំម្ចាស់បានសួរប្រស្នា ១ ទៀតថា
សភាវតែ ១ ពុំមានហើយពុំមានដោយវិសេសជាងសភាវឯទៀត

គឺសភាវអ្វី គ្រុឌឆ្លើយថាមរណធម៌ឈ្មោះថាខ្យល់ដង្ហើមចេញនៃសត្វទាំងពួង បានឈ្មោះថាសភាវពុំមានដ៏ក្រៃលែង ។

តាបសឫសីសួរគ្រុឌវិញថា ម្នាលគ្រុឌពាក្យនេះអ្នកឯងបានពោលមែនឬ ។

គ្រុឌពោលថាខ្ញុំម្ចាស់បានពោលមែន ។

តាបសឫសីស្តាប់ហើយពោលថា ម្នាលគ្រុឌអ្នកឯងពុំដឹងមែន អ្នកឯងត្រូវស្តាប់ពាក្យអធិប្បាយអាត្មាវិញ បណ្តាព្រះអរិយសាវកទាំងឡាយ លោកបានបំរើននូវវិបស្សនាហើយបាននូវបឋមឈានដរាបដល់បញ្ចមឈាន ហើយដល់នូវសោ-តាបត្តិផល សកិទាគាមិផល អនាគាមិផល អរហត្តផលហើយបាននិព្វានទៅ ខន្ធទាំងឡាយ ៥ មានរូបខន្ធជាដើមក៏រលត់សូន្យអស់ទៅ អាការទាំងឡាយ ៣២ មានសក់ជាដើមដ៏សេសសល់ក៏រលត់សូន្យអស់ទៅ បំណែកខាងព្រះពុទ្ធនឹងព្រះបច្ចេកពុទ្ធនឹងពុទ្ធសាវកទាំងឡាយ លោកក៏បានចូលនិព្វានទៅ បានឈ្មោះថាមិនមានហើយ មិនមានក្រៃលែង ម្នាលគ្រុឌដ៏បំរើនពាក្យដែលអ្នកពោលថា មរណធម៌ឈ្មោះ

ជាខ្យល់ផង្អើមបេញ ឈ្មោះថាមិនមានដ៏ក្រៃលែងនោះ ខុសទេគ្រុឌ ។

គ្រានោះសត្វកណ្ដុរបធំក៏ទ្បស៊ព្ទសាធុការថាសាធុ ៗ ប្រពៃហើយ ៗ ។

ទេវតាទាំងឡាយដែលនៅក្នុងព្រៃនោះ ក៏ឡស៊ព្ទសាធុការព្រមគ្នាដ៏មានសំឡេងញាប់ញ័រទាំងផែនដីជាអស្ចារ្យក្រៃពេក ។

ក្នុងខណនោះ កណ្ដុរបធំ បានពោលនូវពាក្យយ៉ាងនេះទៅនឹងគ្រុឌថា ភោគុរុឡ ម្នាលគ្រុឌដ៏ចំរើន ប្រស្នាទាំង ៤ បំពួកនេះអញបានសួរហើយ អ្នកឯងមិនអាចដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានោះ ពាក្យអ្នកឯងមិនត្រូវសមតាមពាក្យព្យាករណ៍របស់តាបសឫសីទេ បើដូច្នេះអ្នកឯងនឹងស៊ីអញឬមិនស៊ីអញទេ ។

គ្រុឌឆ្លើយថាអញមិនត្រូវការនឹងស៊ីអ្នកឯងដែរ ។

កាលនោះតាបសឫសីបានឡឪវាទដល់សត្វគ្រុឌថា ម្នាលគ្រុឌចាប់ដើមអំពីថ្ងៃនេះទៅ អ្នកឯងត្រូវបរិភោគតែអាហារដែលគួរ អាហារឯណាដែលពុំគួរអ្នកឯងកុំបរិភោគឡើយ ហើយអ្នកត្រូវរក្សាសីល ៥ នេះឡជាប់កុំប្រហែសធ្វេសឡើយ ។

សត្វគ្រុឌក៏បានទទួលតាមឱវាទហើយថ្វាយបង្គំលាតាបសឫសី ធ្វើប្រទក្សិណ ៣ ជុំហើយហើរទៅកាន់ទីលំនៅរបស់ខ្លួនវិញ ។

ឯសត្វកណ្ដុបធំក៏ថ្វាយបង្គំលាតាបសឫសី ហើយហើរទៅកាន់ទីលំនៅរបស់ខ្លួនវិញហោង ។

សម្ដេចព្រះមុនីន្ទជិនស្រីសាស្ដាចារ្យជាម្ចាស់ ព្រះអង្គទ្រង់នាំព្រះធម្មទេសនានេះមកសំដែងចប់ហើយ ទ្រង់ពោលនូវបទព្រះគាថាជាទីបំផុតថា៖

ជនិកាចមហាមាយា បិតាសុទ្ធោទនោអហុ
ពារាណសិភូមិបាលោ អានន្ទោកនិដ្ឋោមម
សលភោចសារីបុត្តោ មោគ្គល្លានោចគរុឡោ
សព្វេចញាតិកាតទា អហេសុំពុទ្ធបរិសា
តាបសោចមហាបញ្ញោ អហមេវតថាគតោ ។

អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ស្ត្រីជាមាតាបង្កើតនៃពោធិសត្វវិលមកឥឡូវនេះបានជាព្រះនាងសិរិមហាមាយាពុទ្ធមាតា កុដុម្ពីក៏ដែលជាបិតានៃពោធិសត្វវិលមកឥឡូវនេះបានជា

ព្រះបាទសុទ្ធោទនជាពុទ្ធបិតា ព្រះបាទព្រហ្មទត្តជាម្ចាស់រក្សានូវផែនដីក្នុងនគរពារាណសី វិលមកឥឡូវនេះបានជាភិក្ខុឈ្មោះអានន្ទជាប្អូននៃតថាគត សត្វកណ្ដុបធំ វិលមកឥឡូវនេះបានជាភិក្ខុឈ្មោះសារីបុត្ត សត្វត្រុឌ វិលមកឥឡូវនេះបានជាភិក្ខុឈ្មោះមោគ្គល្លាន ញាតិទាំងឡាយទាំងពួងក្នុងកាលនោះ វិលមកឥឡូវនេះបានជាពុទ្ធបរិសទ្យទាំងអស់ បំណែកខាងតាបសឫសីដែលមានប្រាជ្ញាច្រើន វិលមកឥឡូវនេះគឺអង្គព្រះតថាគតនេះឯង ។

(សម្ដែងរឿងប្រស្នាសត្វកណ្ដុបនឹងសត្វត្រុឌក្នុងសលភជាតកចប់សេចក្ដីដាសង្ខេបតែប៉ុណ្ណោះ)

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

## រឿងបុរសបីនាក់វិវាទគ្នា

មានរឿងមួយថាមានបុរសបីនាក់វិវាទប្រាថ្នាដណ្ដើមដម្ណេកគ្នាចង់ដេកកណ្ដាល បុរសទាំងបីនោះក្រវើនតែប្រកែកជជែកទៅវិញទៅមកនឹងគ្នា ខានពុំបានដេកយប់នោះឡើយ លុះព្រឹកហើយនាំគ្នាទៅដល់ចៅក្រម ហើយប្ដឹងដោយដំណើរទីទៃ ៗ ចៅក្រមពិចារណាពុំដាច់ស្រេចឡើយ ទើបចៅក្រមនាំបុរសទាំងបីទៅក្រាបទូលសម្ដេចព្រះមហាក្សត្រាធិរាជ ដោយដំណើរទីទៃ ៗ នោះហើយព្រះអង្គទ្រង់ព្រះបិត្ដាដោយព្រះប្រាជ្ញាឈ្វេងយល់ក្នុងព្រះរាជហឫទ័យ ហើយព្រះអង្គមានព្រះបន្ទូលថានាព្រះស្ដែងទាំងបីដណ្ដើមដម្ណេកចង់ដេកកណ្ដាលនេះ អញបង្គាប់ឲ្យព្រះស្ដែងបានហោង ចូរព្រះស្ដែងទាំងបីដេកយកក្បាលឈមជុំបូលផងគ្នា នោះសឹងដេកកណ្ដាលគ្រប់គ្នាហោង ឯបុរសទាំងបីស្ដាប់ព្រះបន្ទូលព្រះមហាក្សត្រាធិរាជ បង្គាប់ដូច្នេះនេះហៅសុគតិគមនំហោង ។ ៚